**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**កិច្ចព្រមព្រៀង**

**រវាង**

**រោងចក្រ អិមធីយេស៍ហ្គាមេន ខេមបូឌា ខូលអិលធីឌី**

**និង**

**តំណាងប្រតិភូបុគ្គលិក និងសហជីពមូលដ្ឋានប្រចាំ**

**រោងចក្រ អិមធីយេស៍ហ្គាមេន ខេមបូឌា ខូលអិលធីឌី**

**ស្តីអំពីការព្យួរកិច្ចសន្យាការងារ**

នៅថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ២០២១ វេលាម៉ោង ០១រសៀល នៅក្នុងរោងចក្រ មានកិច្ចប្រជុំមួយរវាងតំណាងក្រុមហ៊ុន និង តំណាងកម្មករនិយោជិត សហជីពមូលដ្ឋានប្រចាំរោងចក្រ ។

នៅក្នុងអង្គប្រជុំនេះ នាយកក្រុមហ៊ុនបានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់អំពីស្ថានភាពបច្ចុប្បន្ននៅក្នុងរោងចក្រដោយសារតែគ្មានការបញ្ជារទិញពីភ្ញៀវហេតុនេះហើយទើបធ្វើអោយផ្នែកខ្លះដំណើរការមិនបាន ដូចនេះក្រុមហ៊ុនសម្រេចធ្វើការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតគ្រប់ផ្នែកទាំងអស់រយះពេល ១២ថ្ងៃគឺចាប់ពីថ្ងៃ១៦ ខែកុម្ភៈ ឆ្នាំ ២០២១រហូតដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២១ នៅក្នុងអំឡុងពេលព្យួរការងារនេះកម្មករនិយោជិតបានឯកភាពទទួលយកនូវការផ្តល់ជូននៅប្រាក់ឈ្នួលចំនួន ២០ដុល្លា ក្នុង០១នាក់ សម្រាប់កម្មករនិយោជិតម្នាក់ៗ ហើយនឹងទទួលបានប្រាក់ពីរាជរដ្ឋាភិបាលតាមសេចក្តីណែនាំ ០៤៥/២០ របស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវះ។

អង្គប្រជុំបានចប់នៅវេលាម៉ោង១៤ និង៣៥នាទី នាថ្ងៃខែឆ្នាំដដែលដោយភាគីទាំងសងខាងមានភាពស្និតស្នាល និងការយោគយល់គ្នាក្រោមស្មារតីទទួលខុសត្រូវ និង សហការគ្នាយ៉ាងរលូន ។

**តំណាងកម្មករ និង តំណាងសហជីព**

**ភ្នំពេញ ថ្ងៃទី ១០ ខែ ០២ ឆ្នាំ២០២១**

**នាយកក្រុមហ៊ុន**

MT.YEN'S GARMENT (CAMBODIA) CO.,LTD.

KINGDOM OF CAMBODIA